បិតុភាពសំរាប់
សារៈប្រយោជន៍របស់កូនអ្នក.....



# អ្វីដែលឪពុកម្តាយ គ្រប់រូបគួរតែដឹង

ឪពុកម្តាយទាំងពីររូបគួរតែបរិច្ចាគ
ដល់សេចក្តីត្រូវការរបស់ កូនអ្នក ។
កូនរាល់ៗរូបគួរគប្បីមានឪពុក
ស្របច្បាប់មួយរូប, គួរដឹងថា
តើនរណាជាឪពុករបស់វា,
ហើយគួរអាចទាមទារ បាន
នូវសិទ្ធិ ព្រមទាំងផលប្រយោជន៍
ដែលជាកម្រៃភ្ជាប់នឹង ការចេះ
ដឹងនេះ ។

Washington State
Department of Social
& Health Services
DCS Division of Child Support

## តើអ្វីជាបិតុភាព?

បិតុភាពស្របច្បាប់មានន័យថា មនុស្សប្រុសដែលជាអ្នកផ្តល់ កំណើតរបស់កូន (ជាឪពុករបស់កូន) ។

## ហេតុអ្វីបានជាខ្ញុំគួរតែបង្កើតសំណុំរឿងបិតុភាព?

ជាការសំខាន់ណាស់ ដែលអ្នកត្រូវតែបង្កើតនូវទំនាក់ទំនង ស្របច្បាប់ រវាងឪពុកនិងកូនម្នាក់ ។ មានឪពុកដ៏ស្របច្បាប់ ម្នាក់គឺមានសារៈប្រយោជន៍ខ្លាំងណាស់សំរាប់កូន ។ សារៈ ប្រយោជន៍ខ្លះៗទាំងនោះមានដូចជា៖

- គ្រូពេទ្យប្រចាំគ្រួសារអាចជួយកូនអ្នកបានកាន់តែប្រសើរ កាលបើគេដឹងអំពីប្រវត្តិដ៏ពេញបរិបូណ៌របស់គ្រួសារក្មេង ។
- កម្រៃជំនួយពីរដ្ឋាភិបាលដូចជាកម្រៃផ្នែកសន្តិសុខសង្គម និងកម្រៃសំរាប់ជនក្រោមបន្ទុកផ្នែកអតីតយុទ្ធជន ដែលអាច មានសំរាប់ក្មេង ។
- ការធានារ៉ាប់រងផ្នែកវេជ្ជសាស្រ្តសំរាប់ក្មេងប្រហែលអាច មានតាមរយៈផែនការសុខភាពរបស់ឪពុក ។
- ការធានារ៉ាប់រងជីវិត និងកម្រៃកេរ្តិ៍មតិ៌កផ្សេងៗទៀតអាចនឹងមានសំរាប់ក្មេង ។
- មាតាបិតាទាំងពីររូបផ្តល់ការជួយឧបត្ថម្ភផ្នែកថវិការ ។

## តើខ្ញុំអាចបង្កើតសំណុំរឿងបិតុភាពរបៀបណា?

មានមធ្យោបាយបីយ៉ាងដើម្បីបង្កើតបិតុភាពស្របច្បាប់ ។

### អាពាហ៍ពិពាហ៍

បើសិនជាមាតានិងបិតារៀបការជាមួយគ្នាមុនកំណើតរបស់កូន អាពាហ៍ពិពាហ៍នោះបង្កើត "សច្ចធារណ៍នៃបិតុ ភាព" នៅក្នុងប្តី ។ ការនេះបានន័យថា ប្តីគឺជាឪពុកស្រប ច្បាប់របស់កូន ។ មាតាបិតាម្ខាងទៀត ឬអ្នកជាប់ទំនាក់ទំនងខ្លះអាចប្តឹងសច្ចធារណ៍នេះនៅក្នុងតុលាការបាន ។

### លិខិតថ្លែងសច្ចាអំពីបិតុភាព

លិខិតថ្លែងសច្ចាអំពីបិតុភាពគឺជាក្រដាសបែបបទដែលជាផ្នែកមួយនៃការទទួលស្គាល់ដំណើរការបិតុភាព ។ ច្បាប់ រដ្ឋចាត់ទុកបុរសដែលចុះហត្ថលេខាលើក្រដាសបែបបទ ថា ជាឪពុកស្របច្បាប់របស់កូន ។ មាតាបិតាទាំងពីរត្រូវតែចុះ ហត្ថលេខាលើក្រដាសបែបបទ ហើយក្រដាសនោះត្រូវតែ មានបោះត្រាសាការី និងមានសំណុំរឿងរក្សាទុកនៅក្នុង ក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីនតោន, មជ្ឈមណ្ឌលសំរាប់ស្ថិតិ សុខភាព (DOH) ។ មន្ទីរពេទ្យអាចផ្តល់សេវាសាការីបានហើយជួយផ្ញើក្រដាសនោះទៅក្រសួង DOH សំរាប់អ្នក ។ ក្រសួង DOH នឹងដាក់ឈ្មោះបុរសដែលចុះហត្ថលេខាជា ឪពុកស្របច្បាប់នៅក្នុងក្រដាសបញ្ជាក់សំបុត្រកំណើត ។

## ដីកាតុលាការ

តុលាការនឹងវិនិច្ឆ័យ ថាតើបុរសនោះជាឪពុករបស់ក្មេងមែន ឬមិនមែន ។ ដើម្បីសម្រេចការនេះ, តាមធម្មតា តុលាការ នឹងតម្រូវឲ្យមានការពិសោធន៍មើលជាតិពន្ធុរបស់ម្តាយ, ឪពុក, និងកូន ។

### ការបង្កើតបិតុភាពដោយប្រើ
### ក្រដាសបែបបទថ្លែងសច្ចាអំពីបិតុភាព

## តើហេតុអ្វីបានជាខ្ញុំត្រូវតែចុះហត្ថលេខាលើលិខិតថ្លែងសច្ចាអំពីបិតុភាព?

ក្រដាសបែបបទនោះគឺងាយ, រហ័ស, ស្របច្បាប់, ហើយជាមធ្យោបាយមានតម្លៃថោកសំរាប់បង្កើតបិតុភាព ។ ចូរចុះហត្ថ លេខាតែពេលណា ដែលបុរសរូបនោះនិងស្ត្រីជាម្តាយដឹង ច្បាស់ប្រាកដថា បុរសនោះជាមនុស្សតែម្នាក់គត់ដែលជា ឪពុករបស់ក្មេង ។

## តើខ្ញុំអាចចុះហត្ថលេខាលើក្រដាសបែបបទថ្លែងសច្ចាអំពីបិតុភាពនៅទីណា?

ឪពុកម្តាយភាគច្រើន ចុះហត្ថលេខាលើក្រដាសនេះនៅនឹងមន្ទីរពេទ្យកំណើតរបស់ក្មេង, នឹងគិលានដ្ឋានកំណើតរបស់ ក្មេង, ឬនឹងផ្ទះកំណើតរបស់ក្មេងក្រោមការគ្រប់គ្រងរបស់ឆ្មប បង្កើតកូន ។

- ប្រសិនបើជាអ្នកត្រូវការជំនួយ, នោះមន្ទីរពេទ្យ, ឆ្មបបង្កើត កូន, ឬបុគ្គលិកគិលានដ្ឋានបង្កើតកូនអាចឆ្លើយនឹងសំនួរអ្នក, ជួយអ្នកបំពេញសំណុំបែបបទ, បោះត្រាសាការីលើសំណុំបែប បទ, ហើយផ្ញើក្រដាសនោះទៅក្រសួង DOH ឲ្យអ្នក ។ ការិយាល័យ DCS, ធនាគារ, និងក្រសួងសុខាភិបាលតាម ស្រុកក៏អាចបោះត្រាសាការីឲ្យអ្នកបានដែរ ។
- ប្រសិនបើអ្នកចុះហត្ថលេខាលើក្រដាសបែបបទក្នុងរវាងប្រាំថ្ងៃនៃកំណើតរបស់កូនអ្នក អ្នកមិនចាំបាច់ត្រូវបង់ថ្លៃសំរាប់ ការតម្កល់ទុកនូវឯកសារសំណុំបែបបទនោះទេ ។
- បើសិនជាអ្នកមិនបានចុះហត្ថលេខាលើក្រដាសបែបបទ នោះនៅនឹងមន្ទីរពេទ្យទេ, អ្នកអាចទៅយកក្រដាសនោះនៅ តាមការិយាល័យក្រសួងសុខាភិបាលមូលដ្ឋានខោនធី ឬតាម ការិយាល័យនាយកដ្ឋានឧបត្ថម្ភក្មេង (DCS) ណាក៏បាន ។ សូមទូរស័ព្ទទៅការិយាល័យ DCS តាមលេខ 800-442-KIDS (5437) ហើយសុំឲ្យគេផ្ញើក្រដាសនោះមកជូនអ្នក ។

## តើខ្ញុំអាចសុំសំណៅចំឡងនៃលិខិតថ្លែងសច្ចាអំពីបិតុភាពមួយច្បាប់បានឬទេ?

បាន ។ ក្រសួង DOH រក្សាទុកសំណៅដើមជាឯកសារផ្លូវ ការ ។ សូមទូរស័ព្ទទៅក្រសួង DOH តាមលេខ 360-236-4300 ហើយសុំសំណៅចំឡងមួយច្បាប់ ឬសួររកកាល បរិច្ឆេទដែលក្រសួង DOH ចុះតម្កល់ក្រដាសបែបបទនោះ ។ ក្រសួង DOH នឹងតម្រូវឲ្យបង់ថ្លៃសំរាប់សេវាថតចំឡង ។

## តើអ្វីខ្លះជាសិទ្ធិស្របច្បាប់របស់ខ្ញុំ កាលណាខ្ញុំចុះហត្ថលេខាលើក្រដាសបែបបទនៃលិខិតថ្លែងសច្ចាអំពីបិតុភាពនោះ?

កាលណាអ្នកចុះហត្ថលេខាលើក្រដាសបែបបទ, ច្បាប់ សហព័ន្ធនិយាយថា អ្នកត្រូវតែទទួលបាននូវពត៌មានស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកជាលាយលក្សអក្សរផង និង ដោយផ្ទាល់មាត់ផង ។ សេចក្តីថ្លែងអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកមាននៅខាងខ្នងនៃក្រដាសបែបបទនោះ ។ ជាការសំខាន់ណាស់ដែលអ្នកត្រូវតែយល់ដឹងនូវអ្វី ដែលគេ និយាយក្នុងក្រដាសនោះ ។

សូមអានមើលសេចក្តីថ្លែងនោះ ហើយជ្រើសរើសធ្វើនូវប្រការ ណាមួយពីចំណោមប្រការទាំងឡាយខាងក្រោមនេះ ៖

- ចូរទស្សនាកាសែតវីដេអូនៅមន្ទីរពេទ្យ, គិលានដ្ឋានបង្កើត កូន, ក្រសួងសុខាភិបាលតាមស្រុករបស់អ្នក, ឬនៅតាមការិ យាល័យនាយកដ្ឋាន DCS ។
- ចូរស្តាប់ពត៌មានស្តីពីការថ្លែងសច្ចាអំពីបិតុភាព ដែល ចាក់ផ្សាយជាស្វ័យប្រវត្តិតាមទូរស័ព្ទមកលេខ 800-356-0463 ។
- ចូរសុំឲ្យនរណាម្នាក់ជួយអាចសេចក្តីថ្លែងបញ្ជាក់នោះឲ្យអ្នក ស្តាប់ ។

កុំចុះហត្ថលេខាលើក្រដាសបែបបទ លុះត្រាតែអ្នក
បានទទួលហើយយល់ដឹងសព្វពត៌មាន
គឺទាំងលាយលក្សអក្សរនិងទាំងផ្ទាល់មាត់ជាមុនសិន ។

## តើខ្ញុំអាចចុះហត្ថលេខាលើលិខិតថ្លែងសច្ចាអំពីបិតុភាពឬទេ បើជាខ្ញុំនៅមានអាយុក្រោម 18 ឆ្នាំ?

បាទបាន ។ លិខិតថ្លែងសច្ចាអំពីបិតុភាពដែលបាន ចុះហត្ថលេខាដោយអនិតិជនគឺស្របច្បាប់ ។ ច្បាប់រដ្ឋចាត់ ទុកអនិតិជន (គឺទាំងបុរសនិងស្ត្រីមានអាយុក្រោម 18 ឆ្នាំ) ដែលចុះហត្ថលេខាលើក្រដាសបែបបទ ថាមានកំរិតទទួលខុសត្រូវដូចគ្នានឹងមនុស្សពេញវ័យ ។

## ចុះបើខ្ញុំមិនប្រាកដថា តើខ្ញុំត្រូវចុះហត្ថលេខាលើលិខិតថ្លែងសច្ចាអំពីបិតុភាព តើវានឹងទៅជាយ៉ាងណាដែរ?

ចូរចុះហត្ថលេខាតែពេលណាដែលអ្នកយល់ថា អ្នកអាចជា ឪពុកពិតប្រាកដតែម្នាក់គត់របស់ក្មេង ។ អ្នកអាចពិគ្រោះយោ បលជាមួយមេធាវីណាម្នាក់ ។ ប្រសិនបើអ្នកសំរេចចិត្តថាមិនចុះហត្ថលេខាលើក្រដាសបែបបទនោះទេ, អ្នកអាចសុំឲ្យ តុលាការបង្កើតសំណុំរឿងបិតុភាពមួយឡើង ។ បើអ្នកមានសំណួរនានា, អ្នកអាចទូរស័ព្ទទៅការិយាល័យ DCS បាន ។ តែការិយាល័យ DCS មិនអាចផ្តល់ដំបូន្មានជូនអ្នកអំពីរឿង រ៉ាវច្បាប់ទម្លាប់បានឡើយ ។

## តើខ្ញុំអាចប្ដូរចិត្តរបស់ខ្ញុំបានទេ ក្រោយពីខ្ញុំបានចុះហត្ថលេខាលើក្រដាស់បែបបទនោះ?

ជនម្នាក់ពីចំណោមបុរសឬស្ត្រីអាចស្នើសុំឲ្យតុលាការដក ឈ្មោះរបស់បុរសចេញពីបញ្ជីកំណើតរបស់ក្មេងបាន ។ អ្នកត្រូវតែសុំតុលាការក្នុងរវាង 60 ថ្ងៃចាប់ពីថ្ងៃដែលក្រសួង DOH បានដាក់តម្កល់សំណុំបែបបទនោះ ។ ភាសាច្បាប់សំរាប់ការដកឈ្មោះអ្នកចេញពីបញ្ជីកំណើតរបស់ក្មេងហៅថា "រំលាយចោល" ("rescind") ។

បើអ្នកឡើងតុលាការដើម្បីសុំដកឈ្មោះជាឪពុករបស់ក្មេង ចេញពីបញ្ជីកំណើត, អ្នកត្រូវតែសុំឲ្យក្រសួង DOH ចេញ សំណៅលិខិតចំឡងផ្លូវការ (certified copy) មួយ ច្បាប់ដល់អ្នក ។ ដើម្បីសុំសំណៅលិខិតចំឡងផ្លូវការ, អ្នកត្រូវការបង្ហាញនូវភស្តុតាងអត្តសញ្ញាណប័ណ្ណ និងបង់ថ្លៃសេវា មួយចំនួន ។ ចូរទូរស័ព្ទទៅក្រសួង DOH ដើម្បីសាកសួរអំពី ចំនួនតម្លៃសេវា ។

## តើខ្ញុំត្រូវជួលមេធាវីណាម្នាក់ ដើម្បីឲ្យគេរំលាយឈ្មោះខ្ញុំចេញពីបញ្ជីកំណើតឬ?

អ្នកត្រូវតែដាក់ពាក្យប្ដឹងទៅតុលាការដើម្បីសុំរំលាយឈ្មោះ អ្នកចេញពីបញ្ជីកំណើត ។ អ្នកអាចធ្វើកិច្ចការនេះដោយខ្លួន ឯងក៏បាន ឬក៏រកជំនួយពីមេធាវីណាម្នាក់ក៏បាន ។ បើតុលា ការអនុញ្ញាតឲ្យមានការរំលាយឈ្មោះអ្នកចេញ, ក្រសួង DOH នឹងដកឈ្មោះអ្នកចេញពីសំបុត្របញ្ជាក់កំណើត ។

## ចុះបើខ្ញុំជាប្ដូរគំនិត ហើយរយៈកាល 61 ថ្ងៃ ឬក៏លើសពីនេះបានកន្លងហួសពីកាលបរិច្ឆេទតម្កល់សំណុំបែបបទលិខិតថ្លែងសច្ចាតើហេតុការណ៍នឹងទៅជាយ៉ាងណាវិញ?

ជនម្នាក់ពីចំណោមបុរសឬស្ត្រីអាចប្ដឹងជំទាស់នឹងលិខិតថ្លែង សច្ចានេះនៅតុលាការបាន ។ អ្នកត្រូវមានភស្តុតាង បង្ហាញ តុលាការថា អ្នកបានចុះហត្ថលេខាដោយសារការ ក្លែងបន្លំ, ការបង្ខិតបង្ខំ, ឬកត្តាភ័ន្តច្រឡំនៃខ្លឹមសារ ។ "កត្តា ភ័ន្តច្រឡំ នៃខ្លឹមសារ" គឺជាមធ្យោបាយស្របច្បាប់មួយដែលនិយាយថា អ្នកបានចុះហត្ថលេខាលើលិខិតថ្លែងបញ្ជាក់ការ ពិតនោះ ដោយសារអ្នកមានជំនឿថាកូននោះជាកូនរបស់អ្នក, តែឥឡូវនេះ អ្នកដឹងរឿងរ៉ាវខ្លះៗអំពីទំនាក់ទំនងរវាងអ្នក និងម្ដាយ ឬរវាងការមានផ្ទៃពោះដែលធ្វើឲ្យអ្នកមានជំនឿថា ការនេះមិនពិតទេ ។

អ្នកមិនអាចប្ដឹងជំទាស់នឹងលិខិតថ្លែងសច្ចាអំពី បិតុភាពបានទេ
បើរយៈកាល 2 ឆ្នាំបានកន្លងហួស
ពីកាលបរិច្ឆេទតម្កល់សំណុំបែបបទទៅហើយនោះ

## បើម្តាយបានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកដ៏ទៃទៀត, តើ ហេតុការណ៍នឹងទៅជាយ៉ាងណាវិញ?

បើសិនជាម្តាយបានរៀបការជាមួយបុរសម្នាក់ផ្សេងទៀត ក្នុងពេលមានផ្ទៃពោះ, ប្តីត្រូវបានគេសន្មត់ (ជឿ) ថាជាឪពុក របស់ក្មេង បើក្មេងកើតមកៈ

- ក្នុងពេលរស់នៅជាមួយគ្នាជាប្តីប្រពន្ធ
- ឬក្នុងរយៈពេល 300 ថ្ងៃ ពីពេលបញ្ចប់អាពាហ៍ពិពាហ៍ ។

បើសិនជាប្តីរបស់ម្តាយយល់ព្រមអនុញ្ញាតឲ្យបុរសម្នាក់ទៀតចុះហត្ថលេខាជាឪពុករបស់ក្មេង, បុរសដែលទាមទារថាជាឪពុក អាចចុះហត្ថលេខាលើលិខិតថ្លែងសច្ចាអំពីបិតុភាព ។ ប្តីរបស់ម្តាយត្រូវតែចុះហត្ថលេខាលើលិខិតបដិសេធបិតុភាព ឬលិខិតថ្លែងសច្ចាអំពីបិតុភាពមិនស្រប ច្បាប់ ។ អ្នកត្រូវតែដាក់ពាក្យទាំងពីរ ទាំងលិខិតថ្លែងសច្ចា និងការ បដិសេធជាមួយក្រសួង DOH ក្នុងរវាង 10 ថ្ងៃ គិតចាប់ ពីថ្ងៃកំណើតក្មេង ។

# ការបង្កើតសំណុំរឿងបិតុភាពនៅតុលាការ

## តើពេលណាតុលាការត្រូវតែបង្កើតបិតុភាព?

អ្នកអាចឡើងតុលាការ កាលណាអ្នកមានជំនឿថា អាចនឹង មានឪពុកលើសពីម្នាក់ ។

## មូលហេតុផ្សេងៗទៀតសំរាប់ការប្រើប្រាស់តុលាការ ដើម្បីបង្កើតសំណុំរឿងបិតុភាពៈ

- ប្រសិនបើជនម្នាក់ពីចំណោមបុរសឬស្ត្រីមិនប្រាកដអំពីការ ចុះហត្ថលេខាលើលិខិតថ្លែងបញ្ជាក់ការពិត
- បើប្តីរបស់ម្តាយមិនសុខចិត្តចុះហត្ថលេខាលើលិខិតបដិសេធ



## តើខ្ញុំត្រូវបើកសំណុំរឿងបិតុភាពនៅតុលាការរបៀបណា?

រដ្ឋអាចបង្កើតបិតុភាព [CS31] សំរាប់កូនរបស់អ្នក បើសិនជាអ្នកដាក់ពាក្យសំរាប់សេវាបង្កើសំណុំរឿងបិតុភាពជាមួយការិយាល័យ DCS ។ សូមទូរស័ព្ទទៅ DCS តាមលេខ 800-442-KIDS (5437) ឬនៅតាមការិយាល័យ DCS ជិតៗអ្នកសំរាប់ពត៌មានបន្ថែមទៀត ។

បើការិយាល័យ DCS ទទួលសំណុំរឿងរបស់អ្នក, យើងនឹង បញ្ជូនសំណុំរឿងរបស់អ្នកទៅមេធាវីរដ្ឋប្រចាំខោនធី ។ មេធា វីរដ្ឋនឹងធ្វើសកម្មភាពក្នុងនាមកូនរបស់អ្នក ហើយគេមិនអាច ធ្វើជាតំណាងឲ្យអ្នកនៅតុលាការ ឬផ្តល់ដំបូន្មានផ្នែកច្បាប់ ទម្លាប់ជូនអ្នកបានទេ ។ មេធាវីរដ្ឋអាចឆ្លើយសំណួរទូទៅអំពី សំណុំរឿងបិតុភាពរបស់អ្នក ។ អ្នកត្រូវតែប្រាប់យើង បើកូន របស់អ្នកទទួលជំនួយសាធារណៈ ឬជំនួយពេទ្យសាស្រ្ត ។

ការិយាល័យ DCS ក៏មានសិទ្ធិទាក់ទងពត៌មានទៅតុលាការ កុលសម្ព័ន្ធដើម្បីបង្កើតសំណុំរឿងបិតុភាពសំរាប់សំណុំរឿង កុលសម្ព័ន្ធខ្លះៗ ។

ចូរពិចារណាអំពីការសួរមេធាវីណាម្នាក់ ដើម្បីរកចំឡើយទាក់ទងផ្នែកច្បាប់ ហើយជាតំណាងអ្នកនៅតុលាការ ។ បើ អ្នកមិនចង់បានសេវារបស់យើងទេ, អ្នកឬមេធាវីរបស់អ្នកអាច ដាក់ពាក្យប្តឹងរកភាពនៃឪពុកម្តាយនៅតុលាការដែលមាន យុត្តាធិការលើករណីនោះ ។

## តើខ្ញុំត្រូវបង្កើតបិតុភាពនៅតុលាការរបៀបណា?

បើសិនជារដ្ឋសាកល្បងបង្កើតសំណុំរឿងបិតុភាព, តាមធម្មតា មេធាវីរដ្ឋនឹងផ្ញើជូនជាផ្លូវការនូវក្រដាសស្នាមផ្នែកច្បាប់ចំ ពោះអ្នកដែលអាចជាឪពុករបស់ក្មេង ។ មេធាវីរដ្ឋ ឬតុលា ការនឹងតំរូវឲ្យម្តាយ, អ្នកដែលអាចជាឪពុក, និងក្មេងធ្វើការ ពិសោធន៍មើលជាតិពន្ធុ ។ តុលាការអាចចេញដីកាឲ្យបង្កើតសំណុំរឿងបិតុភាព ។

## តើអ្វីជាការពិសោធន៍ជាតិពន្ធុ ហើយតើខ្ញុំត្រូវតែធ្វើការពិសោធន៍នេះឬ?

ពន្ធុជាផ្នែកជាលិកានៃរាងកាយរបស់យើង ។ ជាលិកានេះ ចំឡងនូវភិនភាគពីឪពុកម្តាយទៅកូនរបស់គេ ។ ការពិ សោធន៍ជាតិពន្ធុ គឺធ្វើឡើងដើម្បីប្រៀបធៀបពន្ធុទាំងឡាយ ។ បើសិនជាពន្ធុមួយចំនួនដូចគ្នា នោះឪពុកម្តាយនិងកូនគឺមានទំនាក់ទំនងជាមួយគ្នា ។ ការពិសោធន៍ជាតិពន្ធុនេះគឺមាន ភាពត្រឹមត្រូវច្បាស់លាស់ណាស់ ។

ការពិសោធន៍ជាតិពន្ធុគឺមើលផ្នែកផ្សេងៗនៃជាលិការបស់ ឪពុក, ម្តាយ, និងកូន ដែលគេបានយកជាលិកានេះដោយ យកសំឡីផ្តិតពីក្នុងមាត់របស់ពួកគេ ។ មន្ទីរពិសោធន៍ជាតិពន្ធុ នឹងចេញរបាយការណ៍ពន្យល់ ថាតើបុរសអាចមានភាពដូចជា ឪពុកបង្កើតរបស់ក្មេងឬក៏អត់ ។ តុលាការតែងតែតំរូវឲ្យធ្វើការពិសោធន៍មើលជាតិពន្ធុនេះ ប្រសិនបើយល់ថា អាចមាន ឪពុកលើសពីម្នាក់ ។

## តើត្រូវបង់ថ្លៃសេវាអ្វីដែរឬទេ ដើម្បីបង្កើតសំណុំរឿងបិតុភាព នៅតុលាការ?

- បើសិនជាមេធាវីរដ្ឋបង្កើតសំណុំរឿងបិតុភាពនៅតុលាការលើ ករណី DCS, នោះអ្នកមិនមានបង់ថ្លៃឈ្នួលដាក់ពាក្យទេ ។ តែប្រហែលអាចមានថ្លៃឈ្នួលផ្សេងទៀត ដែលទាក់ទងនឹង ការបង្កើតបិតុភាពនៅតុលាការ ។
- បើអ្នកជួលមេធាវី, អ្នកត្រូវទទួលខុសត្រូវលើថ្លៃឈ្នួល និង ថ្លៃតុលាការ ។
- បើបុរសនោះត្រូវបានគេកំណត់ថាជាឪពុក, តុលាការអាច នឹងចេញដីកាឲ្យគាត់បង់ប្រាក់សំរាប់ការពិសោធន៍មើលជាតិ ពន្ធុ ឬថ្លៃឈ្នួលតុលាការ ។

មានរឿងរ៉ាវច្រើនទៀតដែលអ្នកត្រូវដឹង

## តើខ្ញុំត្រូវបង្កើតសិទ្ធិជាឪពុកម្តាយ ដូចជាការគ្រងរក្សា និងការ ទៅលេងសួរសុខទុក្ខរបៀបណា?

មានតែតុលាការទេ ដែលអាចលើកឡើងអំពីបញ្ហាគ្រប់គ្រង រក្សា និងការទៅលេងសួរសុខទុក្ខស្របច្បាប់បាន ។ ការនេះ អាចធ្វើទៅបានតាមរយៈផែនការសំរាប់មាតាបិតា ។ បើអ្នកនិងឪពុកម្តាយដ៏ទៃទៀតមិនអាចសំរេចអំពីបញ្ហាគ្រប់គ្រងរក្សា ឬការទៅលេងសួរសុខទុក្ខបានទេ, សូមទាក់ទងមេធាវី, អ្នកសម្របសម្រួល, ឬអ្នកសម្រួលការងារតុលាការ ។

- ដើម្បីនិយាយជាមួយអ្នកសម្របសម្រួល, សូមទូរស័ព្ទទាក់ ទងក្រុមការងារដំណោះស្រាយវ៉ាស៊ីនតោន, ដែលជាមជ្ឈ មណ្ឌលដោះស្រាយជំលោះទូទាំងរដ្ឋ, តាមទូរស័ព្ទលេខ 800-280-4770 ។
- ដើម្បីស្វែងរកអ្នកសម្រួលការងារតុលាការ, ចូរទូរស័ព្ទទាក់ ទងជាមួយការិយាល័យក្រឡាបញ្ជីរបស់តុលាការដំបូង ។

ដើម្បីជ្រាបនូវពត៌មានបន្ថែម, សូមទូរស័ព្ទទាក់ទងជាមួយ ការិយាល័យ DCS, សួរគេអំពីកូនសៀវភៅមានចំណងជើងថា "តើខ្ញុំអាចធ្វើអ្វីបាន ដើម្បីឲ្យខ្ញុំអាចទៅមើលកូន របស់ខ្ញុំ ឬទៅមើលពួកគេឲ្យបានញឹកញាប់? ការឧបត្ថម្ភក្មេង, ការទៅលេងសួរសុខទុក្ខ, និងការគ្រងរក្សា" ។

## តើខ្ញុំអាចបង្កើតសំណុំរឿងបិតុភាពបានទេ បើឪពុកឬម្តាយរស់នៅក្នុងរដ្ឋផ្សេងទៀត?

បាន ។ ឪពុកឬម្តាយដែលរស់នៅក្នុងរដ្ឋផ្សេងទៀតអាចចុះ ហត្ថលេខាលើលិខិតថ្លែងសច្ចាបាន ។ រដ្ឋដ៏ទៃទៀត ធ្វើការជាមួយ DCS ដើម្បីទទួលដីកាបិតុភាពសំរាប់ក្មេង ដែលកើតនៅក្នុងឬក្រៅរដ្ឋវ៉ាស៊ីនតោន ។

## តើនរណាអាចជួយខ្ញុំបង្កើតសំណុំរឿងបិតុភាព ឬឆ្លើយនឹងសំណួររបស់ខ្ញុំ?

- សូមទូរស័ព្ទទៅលេខ 800-442-KIDS (5437) ឬអាច អានមើលនៅខាងខ្នងនៃកូនសៀវភៅនេះ សំរាប់រកលេខ ទូរស័ព្ទនៃការិយាល័យ DCS ដែលនៅជិតអ្នក ។
- និយាយជាមួយមេធាវីណាម្នាក់ ។
- សូមទូរស័ព្ទទៅលេខ 1-888- 201-1014 ទៅការិយា ល័យ CLEAR (ប្រព័ន្ធសម្រួលផ្នែកច្បាប់, អប់រំ, ឲ្យដំបូន្មាន, និងបញ្ជូន) ។
- បើអ្នករស់នៅក្នុងខោនធីឃីង, សូមទូរស័ព្ទទាក់ទងជាមួយសមាគមមេធាវីតាមលេខ 206-623-2551 ដើម្បីសាកសួររកការជួយផ្នែកច្បាប់ដែលអស់តម្លៃឈ្នួលតិច ។

ការិយាល័យ DCS

| | |
|---|---|
| **Everett** | **800-729-7580**<br>**425-438-4800** |
| **Fife** | **866-243-4449**<br>**253-922-0454** |
| **Kennewick** | **800-345-9981**<br>**509-374-2000** |
| **Olympia** | **800-345-9964**<br>**360-664-6900** |
| **Seattle** | **800-526-8658**<br>**206-341-7000** |
| **Spokane** | **800-345-9982**<br>**509-363-5000** |
| **Tacoma** | **800-345-9976**<br>**253-597-3700** |
| **Vancouver** | **800-345-9984**<br>**360-696-6100** |
| **Wenatchee** | **800-535-1113**<br>**509-886-6800** |
| **Yakima** | **800-441-0859**<br>**509-249-6000** |
| **Headquarters** | **800-457-6202**<br>**360-664-5000** |

អ៊ីម៉ែល **(E-mail)** **dcs-cru@dshs.wa.gov**

Washington State
Department of Social
& Health Services

DCS Division of Child Support